**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍សិក្ខាសាលា

**ក្រុមប្រឹក្សាបច្ចេកទេសលើកទី៥ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨**

**រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ឧបត្ថម្ភដោយ៖ ថវិកាជាតិ**

**១. សេចក្តីផ្តើម៖**

នៅព្រឹកថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៥ សម្រាប់ឆ្នាំ២០១៨ ក្រោមការដឹកនាំរបស់ **ឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

**២. គោលបំណងនៃកិច្ចប្រជុំ៖**

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីសេចក្តីសម្រេចចិត្ត របស់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៨។

-ការពិនិត្យឆ្លងរបាយការណ៍ នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៨។

**៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

ប្រធានបទទី១: ឯកឧត្តមវេជ្ជបណ្ឌិត **ឌា ចៅ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើសកម្មភាពក្នុងខែមិថុនា ឆ្នាំ២០១៨ ដូចខាងក្រោម៖

- ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ នាយកដ្ឋានសុខាភិបាលអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុក្រសួងការពារជាតិ សហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការAHF បាន

ចុះពិនិត្យមើលការធ្វើតេស្តឈាមរកមេរោគអេដស៍ ដល់កងយោធពលខេមរភូមិន្ទ និងគ្រួសារ ចំនួន២០០នាក់ នៅកងវរៈសេនាតូចលេខ២ ការពារព្រំដែនកម្ពុជា ថៃ ច្រកអានសេះ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

- នាព្រឹកថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការសង្គមស៊ីវិលប្រមាណជា១៧០រូប បានចូលរួម។ កិច្ចប្រជុំបានពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ រយៈពេល៦ខែដើមឆ្នាំ២០១៨ និងទិសដៅបន្តរយៈពេល៦ខែចុងឆ្នាំ២០១៨។ ជាមួយគ្នានេះ អង្គប្រជុំក៏បានអនុម័តនូវសេចក្តីសម្រេចចិត្តចំនួន១០ចំណុច សម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការសង្គមស៊ីវិល ចូលរួមអនុវត្តជាបន្តទៀតក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។

  បន្ទាប់មកទៀតនៅពេលរសៀលថ្ងៃ ខែ ឆ្នាំដដែល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានរៀបចំពិធីអបអរសាទរសមិទ្ធផល២៥ឆ្នាំ នៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាលក្ខណៈពហុវិស័យ និងការប្តេជ្ញាចិត្តឆ្ពោះទៅបញ្ចប់ការរីករាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥។

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសេចក្តីព្រាងសម្រាប់ការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការធ្វើផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣)។
- បានរៀបចំសេចក្តីព្រាងបង្កើតក្រុមការងារ (Steering Committee) និងក្រុមការងារយុទ្ធសាស្ត្រ(Strategic Working Goup) សម្រាប់ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការធ្វើផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥។
- បានប្រជុំពិភាក្សាជាមួយតំណាង UNAIDS និង HP+ រៀបចំផែនការថវិកាសម្រាប់ដំណើរការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការធ្វើផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោអេដស៍ និងជំងឺអេដស៍លើកទី៥។
- រាជធានីភ្នំពេញ ព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ មានពិធីផ្ទេរភារកិច្ចថ្នាក់ដឹកនាំមណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិចខាងលិច ដោយឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងទទួលភារកិច្ចជំនួសចាប់ពីខែកក្កដា ឆ្នាំ២០១៨ ។

- ព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើការអប់រំផ្សព្វផ្សាយពីស្ថានភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ដល់និស្សិតចំនួន១៥០នាក់។
- ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយទីចាត់ការសុខាភិបាល អគ្គបញ្ជាការដ្ឋាន នៃកងយុទ្ធពលខេមរភូមិន្ទ និងអង្គការAHF បានរៀបចំការអប់រំផ្សព្វផ្សាយស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដល់មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៅបញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋានកងយោធពលខេរភូមិន្ទ។
- ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ ក្រសួងទេសចរណ៍សហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាស្តីពីការបង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងវិស័យទេសចរណ៍ នៅខេត្តកំពង់ធំ ដោយមានអ្នកចូលរួមចំនួន៨០នាក់។
- រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមសិក្ខាសាលាស្តីពីការចូលរួមបញ្ចប់អេដស៍ របស់ម្ចាស់សេវា និងអ្នកផ្តល់សេវាតាមរយៈការកាត់បន្ថយការមាក់ងាយ និងរើសអើង ចំពោះស្ត្រីធ្វើការនៅសេវាកំសាន្តសប្បាយ។ ម្ចាស់គ្រឹះស្ថានសេវាកំសាន្តសប្បាយ ជាចំណែកមួយដ៏សំខាន់ក្នុងការបញ្ចប់បញ្ហាអេដស៍បាន ដោយគ្រាន់តែផ្តល់ឱកាសដល់ក្រុមការងារអប់រំផ្សព្វផ្សាយ និងការលើកទឹកចិត្តដល់ប្អូនៗដែលធ្វើការនៅទីនោះ អោយបានទទួលការអប់រំយល់ដឹងពីការបង្ការ ការចម្លងនៃមេរោគអេដស៍ នោះគឺជាការចូលរួមចំណែកមួយដ៏ធំសម្រាប់ការបិទបញ្ចប់ពីបញ្ហាអេដស៍ នាឆ្នាំ២០២៥។
- ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចុះសួរសុខទុក្ខ សំណេះសំណាល និងពិនិត្យការផ្តល់សេវា ដល់អ្នកដែលមកទទួលសេវាព្យាបាលនៅមន្ទីរពេទ្យបង្អែករកា ស្ថិតនៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង។
- ព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ នៅខេត្តកំពង់ស្ពឺ ក្រសួងទេសចរណ៍ សហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងរដ្ឋបាលសាលាខេត្ត បានរៀបចំសិក្ខាសាលាស្តីពីការបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងវិស័យទេសចរណ៍ ដោយមានការអញ្ជើញចូលរួមពីអាជ្ញាធរពាក់ព័ន្ធ ម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ និងម្ចាស់សេវាកំសាន្តសប្បាយ ប្រមាណជា៧០នាក់។

## ផែនការសកម្មភាព និងទិសដៅសម្រាប់អនុវត្តបន្ត

- បន្តរៀបចំក្រុមការងារសម្រាប់ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងការធ្វើផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥។
- នឹងបញ្ចប់គម្រោង (Concept note: TOR) សម្រាប់ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងរៀបចំធ្វើផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥។
- នឹងបញ្ចប់ផែនការថវិកា សម្រាប់ដំណើរការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងរៀបចំធ្វើផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** ក៏បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានអនុវត្តកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

- **តំណាងក្រសួងផែនការ៖**

  ✓ ថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅទីប្រជុំជន នៅខេត្តកំពង់ចាម ដោយមានការចូលរួមពីមន្ទីរផែនការរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធមកពីខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងរាជធានីភ្នំពេញ។

  ✓ ថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅទីប្រជុំជន នៅខេត្តសៀមរាប ដោយមានការចូលរួមពីមន្ទីរផែនការខេត្ត និងអ្នកពាក់ព័ន្ធ មកពីខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

- **តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគៈ**

  ការឈានឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅ៩០-៩០-៩០ (មានន័យថា ៩០%នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩០%នៃអ្នកដែលបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ប្រកបដោយគុណភាព និងមិនត្រូវបាត់ពីការព្យាបាល និង៩០%នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ គឺទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយបន្ទុកមេរោគអេដស៍នៅក្នុងខ្លួន)។ គិតត្រឹមឆ្នាំ២០១៧ ចំពោះ ៩០ ទី១ យើងសម្រេចបាន៨៦% ៩០ ទី២ យើងសម្រេចបានរហូតដល់៩៧% និង៩០ ទី៣ យើងសម្រេច

បាន៨០%។ សម្រាប់ឆ្នាំ២០១៧កន្លងទៅ ការធ្វើតេស្តឈាមរកឃើញអ្នកផ្ទុកមេរោគអេដស៍ចំនួន៣៥០០នាក់ ដោយបានយកមកព្យាបាល និងតាមរកដៃគូដើម្បីយកមកធ្វើតេស្តឈាមរកមេរោគអេដស៍ ហើយយោងតាមការវិភាគប្រភពឃើញថា៣០% ចេញពីក្រុមប្រឈមមុខខ្ពស់ គឺស្ត្រីបំរើសេវាកំសាន្តសប្បាយ ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ក្រុមបុរសស្រលាញ់បុរស និង៧០%ចេញពីប្រជាជនទូទៅ។

- **តំណាងអង្គការ KHANA**: បានទទួលមូលនិធិសាកលចំនួន៣ឆ្នាំបន្ត ដោយធ្វើនៅខេត្តកំពង់ស្ពឺ ខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកោះកុង និងខេត្តព្រះសីហនុ។ ចំពោះក្រុមប្រឈមមុខខ្ពស់ធ្វើនៅ៧ខេត្ត ដោយសហការជាមួយអង្គការ CWPD & Men Health។

សម្រាប់ការធ្វើតេស្តឈាមរកមេរោគអេដស៍ពីខែឧសភា ដល់ខែមិថុនា ឆ្នាំ២០១៨៖

- ✓ ក្រុមប្រជាជនទូទៅ: បានធ្វើតេស្តចំនួន១៧៩៥នាក់ តេស្តប្រតិកម្មចំនួន៤នាក់ ក្នុងនោះតេស្តបញ្ជាក់ចំនួន៣នាក់។
- ✓ ក្រុមបុរសស្រលាញ់បុរស: បានធ្វើតេស្តចុងម្រាមដៃចំនួន៣៥២នាក់ តេស្តប្រតិកម្មចំនួន១៩នាក់ ក្នុងនោះតេស្តបញ្ជាក់ចំនួន១៩នាក់។
- ✓ ក្រុមបំលែងភេទ: បានធ្វើតេស្តចំនួន១៥៦នាក់ តេស្តប្រតិកម្មចំនួន៣នាក់ ក្នុងនោះតេស្តបញ្ជាក់ចំនួន៣នាក់។

<u>ប្រធានបទទី២</u>៖ ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញ និងបកស្រាយពីសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៨ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី ជូនដល់សមាជិក សមាជិកាទាំងអស់ ដើម្បីជួយដល់ការរៀបចំធ្វើផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន អោយស្របទៅនឹងសេចក្តីសម្រេចចិត្តនេះ។

<u>ប្រធានបទទី៣</u>៖ ការបង្ហាញពីពង្រាងរបាយការណ៍ នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៨ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដោយលោកវេជ្ជ. **ទេព ណារ៉ាឌុធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ ក្នុងគោលបំណងប្រមូលនូវសកម្មភាពដែលបានអនុវត្តកន្លងមកពីក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល ដើម្បីរៀបចំជារបាយការណ៍ពេញលេញសម្រាប់កិច្ចប្រជុំពេញអង្គនេះ។

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបជូនដល់សមាជិក សមាជិកានៃអង្គប្រជុំថា កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៦ នឹងប្រព្រឹត្តទៅនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង១០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

ឧបសម្ពន្ធ៖

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃពុធ ៧រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨

បានឃើញ និងឯកភាព
**អគ្គលេខាធិការ**

វេជ្ជ.តៀង អគ្គី

បានពិនិត្យត្រឹមត្រូវ
ស. ប្រធាននាយកដ្ឋាន
ទាក់ទង និងចលនាប្រភពធនធាន

អ្នកធ្វើរបាយការណ៍